3/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**សំណុំរឿងរដ្ឋប្បវេណី**
លេខៈ ១៣២
ចុះថ្ងៃទី ០៩ ខែមិនា ឆ្នាំ២០២១
**សាលដីកា**
លេខៈ ១០ក្រIII "អប"
ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២១

# តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃពុធ ១២ កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២១ ដែលមានសមាសភាពដូចខាងក្រោមៈ

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ប្រធានក្រុមប្រឹក្សា
ឯកឧត្តម ចៅក្រុមប្រឹក្សា
លោក ចៅក្រុមប្រឹក្សា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

### ១. អត្តសញ្ញាណរបស់គូភាគី

-ដើមចោទឈ្មោះ [redacted] **សាវ៉េត** ភេទប្រុស អាយុ ៦០ឆ្នាំ មុខរបរ នៅផ្ទះ មានអាសយដ្ឋាន (ស្នាក់នៅផ្ទះប្អូន) [redacted] ឪពុកឈ្មោះ [redacted] **ធៀវ** (ស្លាប់) ម្តាយឈ្មោះ [redacted] **កង** (ស្លាប់) ប្រពន្ធឈ្មោះ [redacted] **សាធឿន** (លែងលះមានសាលក្រម) មានកូន ០៤នាក់។

មានមេធាវីឈ្មោះ [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ។

-ចុងចម្លើយឈ្មោះ [redacted] **ទិច្ឆិកា** ភេទប្រុស អាយុ ៣០ឆ្នាំ មុខរបរ បុគ្គលិកធនាគារអេស៊ីលីដា មានអាសយដ្ឋាននៅ [redacted] ឪពុកឈ្មោះ [redacted] **សាវ៉េត** (រស់) ម្តាយឈ្មោះ [redacted] **សាធឿន** (រស់) នៅលីវ។

### ២. ខ្លឹមសារសាលក្រមដែលដើមចោទតវ៉ា

១-លុបចោលប្រទានកម្ម ដីស្រែមានទំហំ ៨ហិកតា ១៤អារ ៧៩សង្ទីអារ មានប័ណ្ណ សម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ០០៨៤៧៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៥ ស្ថិតនៅភូមិអូតាមោ ឃុំមនោរម្យ ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលបានឲ្យទៅកូនឈ្មោះ [redacted] **ច្ឆិកា** កាលពីកន្លងមក និងសុំឲ្យទទួលស្គាល់ខ្លួនជាម្ចាស់កម្មសិទ្ធិករដូចដើមវិញ។



Scanned with CamScanner

២-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

### ៣. អង្គហេតុបញ្ជាក់ការទាមទារ

នៅឆ្នាំ២០១៣ ឈ្មោះ [redacted] **សាវ៉េត**(ដើមចោទ) ក្រោយពីបានធ្វើផ្លូវមួយខ្សែប្រវែង ៩៧២៩ម៉ែត្រ នៅក្នុងឃុំ និងបានសាងសង់ស្នាក់ការគណបក្សឃុំមនោរម្យ ស្រុកស្វាយទាប ខេត្តស្វាយរៀង ជាមួយក្រុមការងារខ្លួនដែលចុះទៅឃុំនោះមក រដ្ឋបាលឃុំក៏បានដោះដូរនូវដីស្រែទំហំ ៨ហិកតា ១៤អារ និង៧៩សង្ទីអារ នៅក្នុងភូមិអូតាមោ ឃុំមនោរម្យ ស្រុកស្វាយទាប ឲ្យមកក្រុមការងារខ្លួនចុះជួយឃុំដែលមានឈ្មោះ [redacted] **សាវ៉េត** និងឈ្មោះ [redacted] **រតនា** ជាប្រធាន និងអនុប្រធានក្រុម ។ ក្រោយមកដីនេះក៏បានទៅលើឈ្មោះ [redacted] **សាវ៉េត** ម្នាក់ឯងវិញ ហើយនៅឆ្នាំ២០១៥ ឈ្មោះ [redacted] **សាវ៉េត** (ដើមចោទ) ក៏បានទៅស្នើសុំចុះបញ្ជីដីនេះជាដីកម្មសិទ្ធិ ។ នៅពេលស្នើសុំចុះបញ្ជីនោះឈ្មោះ [redacted]**វិច្ឆិកា** (ចុងចម្លើយ) ជាកូនបានសំណូមពរសុំឲ្យចុះឈ្មោះគេជាកម្មសិទ្ធិវិញ ដើម្បីយកប្លង់ដីនេះដាក់ធានាខ្ចីប្រាក់ពីធនាគារដែលកូនធ្វើការមកពង្រីកមុខរបរដែលមានស្រាប់បន្ថែមទៀត ។ ដោយមានសំណូមពរដូច្នេះឈ្មោះ [redacted]**សាវ៉េត**(ដើមចោទ) ក៏យល់ព្រមធ្វើប្លង់ដីស្រែនេះចុះឈ្មោះកូន ហើយក្រោយពីនោះមកឈ្មោះ [redacted]**សាវ៉េត** ក៏ទទួលបានប្លង់ដីនេះពីរដ្ឋបាលសុរិយោដីដោយក្នុងប័ណ្ណនោះបានចុះឈ្មោះ [redacted] **វិច្ឆិកា** ជាកម្មសិទ្ធិ តែប័ណ្ណនេះពុំប្រគល់ទៅកូននោះទេ គឺឈ្មោះ [redacted]**សាវ៉េត** គ្រប់គ្រងរហូតមក ។ នៅឆ្នាំ២០១៦ ដោយសារមានទំនាស់ក្នុងគ្រួសារដើមចោទពុំអាចរស់នៅបានក៏បានចុះចេញពីផ្ទះមកស្នាក់នៅខាងក្រៅមានតែរថយន្ត១គ្រឿង ឯទ្រព្យក្រៅពីនេះទាំងអស់ និងផ្ទះដីភូមិព្រមទាំងមុខរបរនៅលើប្រពន្ធគ្រប់គ្រង ។ ដោយសារជីវភាពជួបការលំបាក និងទីទាល់ក្រខ្លាំងដើមចោទក៏បានលក់ដីស្រែទំហំ ៨ហិកតា ១៤អារ ៧៩សង្ទីអារដែលបានធ្វើប្លង់ចុះឈ្មោះកូននោះទៅអ្នកដទៃក្នុងតម្លៃសរុប ១៦.០០០ដុល្លារអាមេរិក ពេលលក់ឈ្មោះ [redacted]**សាវ៉េត** ក៏បានប្រាប់ទៅកូនឈ្មោះ [redacted]**វិច្ឆិកា**(ចុងចម្លើយ) និងប្រពន្ធខ្លួនក៏បានដឹងផងដែរ កាលនោះប្តីប្រពន្ធអ្នកទាំងពីរនៅមិនទាន់ដាក់បណ្តឹងលែងលះគ្នាមកតុលាការនោះនៅឡើយ ហើយចំពោះប្រាក់បានពីការលក់ដីនេះឈ្មោះ [redacted]**សាវ៉េត** (ដើមចោទ) ក៏បានយកទៅសងបំណុលគេរួមនឹងដោះស្រាយជីវភាពខ្លួនខ្វះខាតពីកន្លងមកនោះអស់គ្មានសល់ ។ នៅពេលថ្មីៗនេះ ឈ្មោះ [redacted]**សាវ៉េត**(ដើមចោទ) ត្រូវរងការប្តឹងចោទប្រកាន់ពីសំណាក់កូនខ្លួនបង្កើតឈ្មោះ [redacted] **វិច្ឆិកា**(ចុងចម្លើយ) ដែលបានប្តឹងពីបទ **លួចលក់អចលនវត្ថុអ្នកដទៃ** ហើយសំណុំរឿងនេះត្រូវបានតំណាងអយ្យការបើកការស៊ើបសួរ និងបញ្ជូនមកចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តស្វាយរៀងកំពុងតែចាត់ការស៊ើបសួរតាមនីតិវិធីច្បាប់ ។ ឯឈ្មោះ [redacted]**សាវ៉េត** (ដើមចោទ) ត្រូវជាឪពុកភាគីចុងចម្លើយពុំអាចទទួលបាននូវករណីកូនបង្កើតខ្លួនប្តឹងខ្លួនពីបទព្រហ្មទណ្ឌយ៉ាងដូច្នេះក៏បានប្តឹងរឿងនេះ មកតុលាការស្នើសុំលុបចោលនូវប្រទានកម្ម(ដីស្រែ)ដែលបានឲ្យទៅកូន និងទាមទារយកដីស្រែដែលជាប្រទានកម្មនោះមកវិញ។

**-បានឃើញ** សាលក្រមរដ្ឋប្បវេណីលេខៈ **៧០ (ក)** ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តស្វាយរៀង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ដូចតទៅ៖

១-ច្រានចោលបណ្តឹងទាមទាររបស់ឈ្មោះ **ទេព សាវ៉េត**(ដើមចោទ)។

២-ឲ្យភាគីដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាលក្រមនេះបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០ ចំពោះមុខឈ្មោះ [redacted] សាវ៉េត(ដើមចោទ) លោក [redacted] មេធាវីតំណាងដោយអាណត្តិភាគីដើមចោទ និងភាគីចុងចម្លើយឈ្មោះ [redacted] វិច្ឆិកា។

-បើកសិទ្ធិឲ្យភាគីប្តឹងឧទ្ធរណ៍តាមបញ្ញត្តិច្បាប់។

**-បានឃើញ** សេចក្តីសុំប្តឹងឧទ្ធរណ៍លេខ ៦៦ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២០ របស់ឈ្មោះ [redacted] **សាវ៉េត** ជាដើមចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ៧០ (ក) ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុចផ្នែកសេចក្តីសម្រេចបញ្ចប់នៃសាលក្រមទាំងមូល។

**អង្គហេតុដែលបានលើកឡើងនាពេលនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**

-ដើមចោទឈ្មោះ [redacted] **សាវ៉េត** បានថ្លែងការណ៍ថា៖ សាលាដំបូងខេត្តសម្រេចសេចក្តីមានការភាន់ច្រឡំ ដោយសារដីនេះខ្លួនទទួលលទ្ធកម្មកម្មសិទ្ធិពីឃុំមនោរម្យ ដែលកាលនោះសាលាឃុំមិនមានថវិកាសាងសង់មន្ទីរបក្ស និងផ្លូវមួយខ្សែមានទទឹងប្រវែង ៨ម៉ែត្រ និងបណ្តោយប្រវែង ៩០០ម៉ែត្រ តាមគំរូឯកភាពរបស់ឯកឧត្តម [redacted] **ឡុងឌី** ។ រឿងនេះប្រពន្ធកូនខ្លួនក៏សុទ្ធតែបានដឹងឮ និងទទួលស្គាល់ ហើយដីនេះក្រោយមកបានលក់ឲ្យឈ្មោះ [redacted] **សៅ** និងឈ្មោះ [redacted] **ជា** ព្រោះដោយសារសងបំណុល និងទូទាត់ ។ ការដាក់ឈ្មោះកូនក៏ដើម្បីខ្ចីប្រាក់មកបង្កើនការរកស៊ី និងសេដ្ឋកិច្ចគ្រួសារដែរ ។ សព្វថ្ងៃខ្លួនជំពាក់បំណុលគេ មានជីវភាពក្រីក្រ មិត្តភ័ក្តមិនរាប់រក គ្មានកាងារធ្វើ បាត់បង់បែកបាក់គ្រួសារ ហើយកូនបានប្តឹងខ្លួនឲ្យគេចាប់ដាក់គុកទៀត ដែលទង្វើនេះមិនអាចទទួលយកបាន ។ ហេតុនេះ ខ្លួនសុំដកហូត និងលុបប្រទានកម្មដីស្រែទំហំ ៨ហិចតានេះ និងសុំទទួលស្គាល់ខ្លួនជាកម្មសិទ្ធិករវិញ។

-ចុងចម្លើយឈ្មោះ [redacted] **វិច្ឆិកា** បានថ្លែងការណ៍ថា៖ ខ្លួនបានទទួលដីស្រែទំហំ ៨ហិតា ១៤អារ ពីឪពុកម្តាយខ្លួនដែលបានឲ្យមកខ្លួនពិតប្រាកដមែន តែឪពុកម្តាយបានលែងលះគ្នាមានសាលក្រមសាលាដំបូង ។ ដីនេះមានសរសេរឈ្មោះខ្លួន មិនមែនធ្វើប័ណ្ណនេះដើម្បីទៅខ្ចីប្រាក់នៅធនាគារដូចការអះអាងរបស់ដើមចោទទេ ។ ក៏ប៉ុន្តែដីស្រែដែលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ខ្លួនមិនបានគ្រប់គ្រងទេ ប័ណ្ណនោះគឺឪពុកខ្លួនជាអ្នកទុកហើយគាត់បានលក់ឲ្យអ្នកដទៃ ទើបខ្លួនប្តឹងគាត់ក្នុងរឿងព្រហ្មទណ្ឌ ។ សំណូមពរ សុំក្រុមប្រឹក្សាតម្កល់សាលក្រមសាលាដំបូងខេត្តស្វាយរៀងលេខ ៧០"ក" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០ ទុកជាបានការ។

-មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ កាលពីឆ្នាំ២០១២ ឈ្មោះ [redacted] **សាវ៉េត** បានធ្វើការសាងសង់ផ្លូវ និងមន្ទីគណៈបក្សឃុំមនោរម្យ ដោយឈ្មោះ [redacted] **សាវ៉េត** បានស្នើសុំឱ្យសាលាឃុំធ្វើបដិភាគមកឱ្យខ្លួនខ្លះ ប៉ុន្តែសាលាឃុំពុំមានលទ្ធភាពធ្វើបដិភាគមកឱ្យឈ្មោះ [redacted] **សាវ៉េត** ក៏បានកាត់ដីស្រែទំហំ ៨ហិកតា ១៤អា ៧៩សងទីអា ដែលមានទីតាំងស្ថិតនៅភូមិអូរតាមោ ឃុំមនោរម្យ ស្រុកស្វាយទាប ខេត្តស្វាយរៀង មកឈ្មោះ [redacted] **សាវ៉េត** ។ អំឡុងខែកញ្ញា ឆ្នាំ២០១៥ ឈ្មោះ [redacted] **សាវ៉េត** ក៏បានស្នើសុំមន្ទីសុរិយោដី ដើម្បីចុះបញ្ជីធ្វើប័ណ្ណកម្មសិទ្ធិ ។ នៅពេលមន្ទីសុរិយោដីចុះធ្វើប័ណ្ណកម្មសិទ្ធិឈ្មោះ [redacted] **សាវ៉េត** ក៏បានដាក់ឈ្មោះ [redacted] **វិច្ឆិកា** កូនប្រុសបង្កើតឈ្មោះ [redacted] **សាវ៉េត** ដោយសារតែឈ្មោះ [redacted] **វិច្ឆិកា** អះអាងខ្លួនធ្វើការងារនៅធនាគារស្រាប់ បើដាក់ឈ្មោះខ្លួនងាយស្រួល នឹងខ្ចីប្រាក់ធនាគារ ។ នៅក្នុងឆ្នាំ២០១៦ ឈ្មោះ [redacted] **សាវ៉េត** បានលក់ដីនេះទៅ

ឱ្យឈ្មោះ [redacted] សៅ និងឈ្មោះ [redacted] ជា ដោយសារតែការរកស៊ីមានខាតបង់ និងជីវភាពគ្រួសារផង ប៉ុន្តែនៅពេលដែលឈ្មោះ [redacted] សាវ៉េត បានលក់ដីនេះក៏បានប្រាប់ឈ្មោះ [redacted] វិច្ឆិកា តែឈ្មោះ [redacted] វិច្ឆិកា មិនបានជំទាស់អ្វីនោះទេ ។ នៅក្នុងអំឡុងឆ្នាំ២០១៧ ដែលសារក្នុងគ្រួសាររបស់កូនក្តីខ្លួន គឺភាពរកាំរកូជាមួយគ្នា ទើបឈ្មោះ [redacted] សារឿន បានសម្រេចចិត្តដាក់ពាក្យបណ្តឹងលែងលះជាមួយកូនក្តីខ្លួនឈ្មោះ [redacted] សាវ៉េត ហើយពាក្យបណ្តឹងត្រូវបានសាលាដំបូងខេត្តស្វាយរៀងសម្រេចតាមអំណាចសាលក្រមលេខ ២៦១(ឆ) ចុះថ្ងៃទី ១៣/១២/២០១៧ នៅថ្ងៃទី ០៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] វិច្ឆិកា ត្រូវជាកូនប្រុសបង្កើតកូនក្តីខ្លួន បានដាក់ពាក្យបណ្តឹងកូនក្តីខ្លួនឈ្មោះ [redacted] សាវ៉េត ពីបទលួចលក់អចលនវត្ថុអ្នកដទៃ និងប្រើប្រាស់ឯកសារសាធារណៈក្លែងទៅអយ្យការអមសាលាដំបូងខេត្តស្វាយរៀង ហើយត្រូវបានអយ្យការអមសាលាដំបូងខេត្តស្វាយរៀង សម្រេចចោទប្រកាន់កូនក្តីខ្លួនតាមដីកាបញ្ជូលរឿងឱ្យស៊ើបសួរលេខ ១៨៩អ.យ.ក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២០ ។ សរុបសេចក្តីរួមមកឃើញថា កូនក្តីខ្លួនឈ្មោះ [redacted] សាវ៉េត ពិតជាម្ចាស់កម្មសិទ្ធិនៅដីទំហំ ៨ហិកតា ១៤អា ៧៩សង្ទីអា ពិតប្រាកដមែន ។ នៅពេលធ្វើចុះបញ្ជីប័ណ្ណកម្មសិទ្ធិជាមួយមន្ត្រីជំនាញឈ្មោះ [redacted] វិច្ឆិកា បានឱ្យកូនក្តីខ្លួនដាក់ឈ្មោះគាត់ ដើម្បីងាយស្រួលខ្ចីលុយពីធនាគារ ពីព្រោះឈ្មោះ [redacted] វិច្ឆិកា ជាបុគ្គលិកនៅធនាគារអេស៊ីលីស្រាប់ ម្យ៉ាងទៀតឈ្មោះ [redacted] វិច្ឆិកា ក្នុងនាមជាកូនប្រុសបង្កើតត្រូវមានកាតព្វកិច្ចចិញ្ចឹមបីបាច់មាតាបិតា ប៉ុន្តែឈ្មោះ [redacted] វិច្ឆិកា បែរជាមកប្តឹងឪពុកបង្កើតឈ្មោះ [redacted] សាវ៉េត ដាក់គុកទៅវិញ ដែលទង្វើនេះជាទង្វើមួយដែលសង្គមខ្មែរស្អប់ខ្ពើម មិនតែប៉ុណ្ណោះបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ កិត្តិយស របស់កូនក្តីខ្លួន ដែលមានច្បាប់ការពារអំពីផលប្រយោជន៍របស់គាត់ ។ ដូច្នេះខ្លួនសូមសំណូមពរ៖

១. លុបចោលប្រទានកម្ម ដីស្រែមួយកន្លែងដែលមានទំហំ ០៨ហិកតា ១៤អា ៧៩សង្ទីអា មានទីតាំងស្ថិតនៅភូមិអូរតាមោ ឃុំមនោរម្យ ស្រុកស្វាយទាប ខេត្តស្វាយរៀង មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ០០៨៤៧៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៥ ពីកូនប្រុសបង្កើតឈ្មោះ [redacted] វិច្ឆិកា។

២. ទទួលស្គាល់ឈ្មោះ [redacted] សាវ៉េត ជាម្ចាស់កម្មសិទ្ធិលើដីស្រែមួយកន្លែងដែលមានទំហំ ០៨ហិកតា ១៤អា ៧៩សង្ទីអា មានទីតាំងស្ថិតនៅភូមិអូរតាមោ ឃុំមនោរម្យ ស្រុកស្វាយទាប ខេត្តស្វាយរៀង មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ០០៨៤៧៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៥។

៣. បង្គាប់ឱ្យមន្ទីររៀបចំដែន នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្វាយរៀង ធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិពីឈ្មោះ [redacted] វិច្ឆិកា មកឱ្យឈ្មោះ [redacted] សាវ៉េត។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## សំអាងហេតុ

១/ សំណុំរឿងរដ្ឋប្បវេណីលេខ ១៣២ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ ជាសំណុំរឿងដែលមានដើមចោទឈ្មោះ [redacted] សាវ៉េត និងចុងចម្លើយឈ្មោះ [redacted] វិច្ឆិកា ហើយសំណុំរឿងនេះត្រូវបានដើមចោទឈ្មោះ [redacted] សាវ៉េត ប្តឹងឧទ្ធរណ៍ទៅនឹងសាលក្រមរដ្ឋប្បវេណីលេខ ៧០-ក- ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តស្វាយរៀង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេចបញ្ចប់។

២/ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦៦ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ **ទេព សាវ៉េត** បានធ្វើឡើងក្នុងកំណត់ច្បាប់ ។ ហេតុដូច្នេះ សាលាឧទ្ធរណ៍អាចធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បាន យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣/ រឿងក្តីនេះ ដើមចោទឈ្មោះ [redacted] **សាវ៉េត** បានប្តឹងទាមទារលុបចោលប្រទានកម្មដីស្រែមានទំហំ ៨ហិចតា ១៤អារ ៧៩សង្ទីអារ មានទីតាំងនៅភូមិអូតាមោ ឃុំមនោរម្យ ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលខ្លួនបានឲ្យទៅកូនឈ្មោះ [redacted] **វិច្ឆិកា** កន្លងមក ជាដីស្រែមានក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ០០៨៤៧៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៥ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្វាយរៀង និងសុំឲ្យទទួលស្គាល់ខ្លួនឈ្មោះ [redacted] **សាវ៉េត** ជាម្ចាស់កម្មសិទ្ធិករដូចដើមវិញ។

៤/ តាមសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] **សាវ៉េត** បានប្តឹងទាមទារថា សាលាដំបូងខេត្តសម្រេចសេចក្តីមានការភាន់ច្រឡំ ដោយសារដីនេះខ្លួនទទួលលទ្ធកម្មកម្មសិទ្ធិពីឃុំមនោរម្យ ដែលកាលនោះសាលាឃុំមិនមានថវិការសាងសង់មន្ទីរបក្ស និងផ្លូវមួយខ្សែមានទទឹងប្រវែង ៨ម៉ែត្រ និងបណ្តោយប្រវែង ៩០០ម៉ែត្រ តាមគំរូឯកភាពរបស់ឯកឧត្តម [redacted] **ឡុងឌី** ។ រឿងនេះប្រពន្ធកូនខ្លួនក៏សុទ្ធតែបានដឹងឮ និងទទួលស្គាល់ ហើយដីនេះក្រោយមកបានលក់ឲ្យឈ្មោះ [redacted] **សៅ** និងឈ្មោះ [redacted] **ដា** ព្រោះដោយសារសងបំណុល និងទូទាត់ ។ ការដាក់ឈ្មោះកូនក៏ដើម្បីខ្ចីប្រាក់មកបង្កើនការរកស៊ី និងសេដ្ឋកិច្ចគ្រួសារដែរ ។ សព្វថ្ងៃខ្លួនជំពាក់បំណុលគេ មានជីវភាពក្រីក្រ មិត្តភ័ក្រ្តមិនរាប់រក គ្មានការងារធ្វើ បាត់បង់បែកបាក់គ្រួសារ ហើយកូនបានប្តឹងខ្លួនឲ្យគេចាប់ដាក់គុកទៀត ដែលទង្វើនេះមិនអាចទទួលយកបាន ។ ហេតុនេះ ខ្លួនសុំដកហូត និងលុបប្រទានកម្មដីស្រែទំហំ ៨ហិចតានេះ និងសុំទទួលស្គាល់ខ្លួនជាកម្មសិទ្ធិករវិញ។

៥/ តាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] **វិច្ឆិកា** បានថ្លែងការណ៍ថា ខ្លួនបានទទួលដីស្រែទំហំ ៨ហិតា ១៤អារ ពីឪពុកម្តាយខ្លួនដែលបានឲ្យមកខ្លួនពិតប្រាកដមែន តែឪពុកម្តាយបានលែងលះគ្នាមានសាលក្រមសាលាដំបូង ។ ដីនេះមានសរសេរឈ្មោះខ្លួន មិនមែនធ្វើប័ណ្ណនេះដើម្បីទៅខ្ចីប្រាក់នៅធនាគារដូចការអះអាងរបស់ដើមចោទទេ ។ ក៏ប៉ុន្តែដីស្រែដែលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ខ្លួនមិនបានគ្រប់គ្រងទេ ប័ណ្ណនោះគឺឪពុកខ្លួនជាអ្នកទុកហើយគាត់បានលក់ឲ្យអ្នកដទៃ ទើបខ្លួនប្តឹងគាត់ក្នុងរឿងព្រហ្មទណ្ឌ ។ សំណូមពរ សុំក្រុមប្រឹក្សាតម្កល់សាលក្រមសាលាដំបូងខេត្តស្វាយរៀងលេខ ៧០"ក" ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០ ទុកជាបានការ។

៦/ តាមសេចក្តីថ្លែងការណ៍របស់មេធាវី [redacted] អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ បានថ្លែងការណ៍បញ្ជាក់មានន័យសង្ខេបឲ្យដឹងថា កូនក្តីខ្លួនបានសាងសង់ផ្លូវ និងមន្ទីរគណៈបក្សឃុំមនោរម្យ ដែលពេលនោះសាលាឃុំត្រូវធ្វើបដិភាគថវិការខ្លះមកឲ្យឈ្មោះ [redacted] **សាវ៉េត** និងក្រុមការងារ ប៉ុន្តែសាលាឃុំពុំមានលទ្ធភាពក៏បានកាត់ដីស្រែទំហំ ៨ហិចតា ១៤អារ ៧៩សង្ទីអារ មានទីតាំងនៅភូមិអូតាមោ ឃុំមនោរម្យ ស្រុកស្វាយទាប ខេត្តស្វាយរៀង ឲ្យទៅឈ្មោះ [redacted] **សាវ៉េត** ។ នៅអំឡុងខែកញ្ញា ឆ្នាំ២០១៥ ឈ្មោះ [redacted] **សាវ៉េត** បានស្នើសុំមន្ទីរសុរិយោដីខេត្តចុះធ្វើប័ណ្ណកម្មសិទ្ធិ និងបានសុំដាក់ឈ្មោះ [redacted] **វិច្ឆិកា** ជាកូនប្រុសបង្កើត ដោយសារតែឈ្មោះ [redacted] **វិច្ឆិកា** ធ្វើការនៅធនាគារស្រាប់ ងាយស្រួលខ្ចីប្រាក់ និងជាក់

ធានាធនាគារ ។ នៅឆ្នាំ២០១៦ កូនក្តីខ្លួនបានលក់ដីនេះឲ្យទៅឈ្មោះ [redacted] សៅ និងឈ្មោះ [redacted] ជា ព្រោះដោយសារសងបំណុល រកស៊ីខាតបង់ និងជីវភាពគ្រួសារ ។ នៅឆ្នាំ២០១៧ កូនក្តីខ្លួនមានបញ្ហានៅក្នុងគ្រួសារ ហើយបានប្តឹងលែងលះមានសាលក្រមលេខ ២៦១(ផ) ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១៧ ។ ក្រោយមកនៅថ្ងៃទី ០៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] វិច្ឆិកា បានដាក់ពាក្យបណ្តឹងកូនក្តីខ្លួនពីបទ លួចលក់អចលនវត្ថុអ្នកដទៃ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ដែលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៨៩អយក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២០ ដែល ទង្វើនេះ នាំឲ្យឈ្មោះ [redacted] សាវ៉េត ជាឪពុកមានការខកចិត្តយ៉ាងខ្លាំង ដែលបានធ្វើឲ្យប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូរ ដែលសង្គមខ្មែរស្អប់ខ្ពើមមិនអាចទទួលយកបាន ដែលកូនបានប្តឹងឪពុកបង្កើតដាក់គុក ។ សព្វថ្ងៃកូនក្តីខ្លួនបានបាត់បង់មុខរបរការងាររកស៊ី គ្រួសារ និងកូនៗ មានជីវភាពទ័លក្រ លំបាក ។ ហេតុដូចនេះ ស្នើសុំក្រុមប្រឹក្សាសម្រេចលុបសាលក្រម និងលុបប្រទានកម្មតាមការប្តឹងទាមទារដូចមានសរសេរនៅក្នុងពាក្យបណ្តឹង និងទទួលស្គាល់ឈ្មោះ [redacted] សាវ៉េត ជាម្ចាស់កម្មសិទ្ធិដីដូចដើមវិញ។

៧/ ក្រោយពីឆ្លងកាត់នីតិវិធីទាញហេតុផលផ្ទាល់មាត់ ក្រោយបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ មេធាវី [redacted] អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ បានស្តាប់សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ និងអំណានកំណត់ហេតុចម្លើយសាក្សី និងពិនិត្យឯកសារនានានៅក្នុងសំណុំរឿងរួច ឃើញថាដើមចោទមានអត្ថិភាពនៃសិទ្ធិទាមទារ ដោយសារមានមូលហេតុត្រឹមត្រូវ។

៨/ ក្នុងរឿងនេះ ចុងចម្លើយបានទទួលស្គាល់ថា ខ្លួនបានទទួលដីស្រែដែលជាកម្មវត្ថុនៃវិវាទថា ជាដីដែលឪពុកបានឲ្យមកខ្លួន ហើយដើមចោទបានបញ្ជាក់ថា ដីស្រែនេះខ្លួនបានទទួលពីសាលាឃុំ មនោរម្យ(ឯកសារលេខ ១៣/១ លេខ ១៣/២ និងលេខ ១៣/៥) ដែលត្រូវចេញថវិការបដិភាគសម្រាប់សាងសង់តែមិនមានប្រាក់បានកាត់ដីឲ្យមែន ហើយនៅឆ្នាំ២០១៥ ដើមចោទបានធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ០០៨៤៧៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៥ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្វាយរៀង ដាក់ឈ្មោះ [redacted] វិច្ឆិកា ពិតមែន ដែលក្រមរដ្ឋប្បវេណីបានចាត់ថា ប្រទានកម្មដែលមិនធ្វើជាលាយល័ក្ខណ៍អក្សរត្រង់មាត្រា ៥៧០។

៩/ តាមពាក្យសុំជូនពិនិត្យភស្តុតាងរបស់មេធាវី [redacted] ត្រង់ចំណុចឯកសារលេខ ៥ លេខ ៦ លេខ ៧ និងលេខ ៨ ក្នុងសំណុំរឿងបានបញ្ជាក់មានន័យសង្ខេបឲ្យបានដឹងថា ឈ្មោះ [redacted] វិច្ឆិកា ពិតជាបានប្តឹងឈ្មោះ [redacted] សាវ៉េត ជាឪពុកក្នុងរឿងព្រហ្មទណ្ឌ ហើយតំណាងអយ្យការបានសម្រេចបើកការស៊ើបសួរឈ្មោះ [redacted] សាវ៉េត ពីបទ លួចលក់អចលនវត្ថុអ្នកដទៃ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅចំណុច ភូមិអូតាមោ ឃុំមនោរម្យ ស្រុកស្វាយទាប ខេត្តស្វាយរៀង ពិតប្រាកដមែន។

១០/ តាមការពិនិត្យប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ០០៨៤៧៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០១៥ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយ៍កម្ម សំណង់ និងសុរិយោដីខេត្តស្វាយរៀង ធៀបទៅនឹងពាក្យបណ្តឹងរបស់ដើមចោទ ដែលបានដាក់មកសាលាដំបូងចុះយកលេខថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០២០ មានរយៈពេល ៤ឆ្នាំ ៦ខែ ១៤ថ្ងៃ មិនទាន់បានហួសរយៈពេលដែលបានចែងត្រង់ មាត្រា ៥៧២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីនៅឡើយទេ។

១១/ ជាសរុបពីចំណុច ៣ ដល់ចំណុច ១០ នៃសំអាងហេតុខាងលើ ក្រុមប្រឹក្សាយល់ឃើញថា ដើមចោទមានអត្ថិភាពនៃសិទ្ធិទាមទារតាមពាក្យបណ្តឹង គប្បីទទួលស្គាល់ ដោយសារមានមូលហេតុ និងហេតុផលត្រឹមត្រូវ រីឯការសម្រេចសេចក្តីនៅក្នុងសាលក្រមរដ្ឋប្បវេណីលេខ ៧០-ក- ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តស្វាយរៀង គប្បីលុបចោល និងសម្រេចជាថ្មី ឯប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ កថាខ័ណ្ឌ ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដូច្នេះ សេចក្តីសម្រេចបញ្ចប់មានដូចខាងក្រោម

## សេចក្តីសម្រេចបញ្ចប់

១/ ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៦៦ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] **សាវ៉េត** ទុកជាបានការ។

២/ លុបសាលក្រមរដ្ឋប្បវេណីលេខ ៧០-ក- ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តស្វាយរៀង ចោលជាអសារបង់។

៣/ លុបចោលនូវប្រទានកម្ម គឺដីស្រែទំហំ ៨ហិចតា ១៤អារ ៧៩សង្ទីអារ មានទីតាំងនៅភូមិអូតាមោ ឃុំមនោរម្យ ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលបានឲ្យទៅកូនឈ្មោះ [redacted] **វិច្ឆិកា** ជាដីស្រែមានក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ០០៨៤៧៣ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៥ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្វាយរៀង ជាអសារបង់ និងទទួលស្គាល់ឈ្មោះ [redacted] **សាវ៉េត** ជាម្ចាស់កម្មសិទ្ធិករដូចដើមវិញ។

៤/ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២១៕

**ចៅក្រមប្រឹក្សា**

ហត្ថលេខា: [redacted]

**ប្រធានក្រុមប្រឹក្សា**

ហត្ថលេខា: [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃចន្ទ ២រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២១

**បានឃើញ**

**ប្រធានក្រុមប្រឹក្សា**

[redacted]

**ក្រឡាបញ្ជី**

[redacted]